**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

**តុលាការរដ្ឋប្បវេណី**

# សាលក្រម

រឿងក្តីលេខ៖ ៨២ ប.អ.ស ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២២ ។

សញ្ញាណនៃរឿងក្តី៖ **លែងលះប្រពន្ធ** ។

ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់៖ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២។

សាលក្រមលេខ **២៣ "ញ"/ ១៦៤**

កាលបរិច្ឆេទនៃការប្រកាសសាលក្រម៖ ថ្ងៃទី១៣ ខែ មិថុនា ឆ្នាំ ២០២២ ។

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

### ចៅក្រមជំនុំជម្រះ

លោក [redacted] ឋានៈចៅក្រមនៃសាលាដំបូងខេត្តសៀមរាប

### ក្រឡាបញ្ជី

លោក [redacted] ឋានៈក្រឡាបញ្ជីនៃសាលាដំបូងខេត្តសៀមរាប

ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ

**ដើមចោទ(ចុងចម្លើយនៃបណ្តឹងតប)**

ឈ្មោះ [redacted] **លឹម** ភេទប្រុស អាយុ៥០ឆ្នាំ(កើតថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៧៣) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ ពេទ្យធ្មេញ អាសយដ្ឋានបច្ចុប្បន្ននៅ[redacted] ។

**ចុងចម្លើយ(ដើមចោទនៃបណ្តឹងតប)**

ឈ្មោះ [redacted] **ស្រីមុំ** ភេទស្រី អាយុ៤៨ឆ្នាំ (កើតថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៧៥) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ នៅផ្ទះ អាសយដ្ឋានបច្ចុប្បន្ន[redacted] ។

**មេធាវីតំណាងដោយអាណត្តិ៖**លោកមេធាវី [redacted] អត្តលេខ ៣១៩ និងលោកមេធាវី [redacted] អត្តលេខ ២៤៨៧T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៅការិយាល័យ[redacted] ។

## អង្គហេតុ និងចំណុចវិវាទ

**ក- ខ្លឹមសារនៃសាលក្រមដែលដើមចោទ(ចុងចម្លើយនៃបណ្តឹងតប)ទាមទារ**

១- ឲ្យដើមចោទឈ្មោះ [redacted] **លឹម** លែងលះពីចុងចម្លើយឈ្មោះ [redacted] **ស្រីមុំ** ។

២- បែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែករួមមាន៖

1. ដីមួយកន្លែង មានទំហំ **២៧១៥ម$^2$** មានទីតាំងស្ថិតនៅភូមិពួកចាស់ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧០៧១០០១-១០១៥ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៩ ។

2. ដីមួយកន្លែង មានទំហំ **១១៤ម²** មានទីតាំងស្ថិតនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៤០៥-០៧០៣ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩ ។
3. ដីស្រែមួយកន្លែង មានទំហំ **៣៧៩៥ម²** មានទីតាំងស្ថិតនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ដែលមានលិខិតសុំបញ្ជាក់ដីធ្លី ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០២១ ។
4. ដីស្រែមួយកន្លែង មានទំហំ **១៩២០ម²** មានទីតាំងស្ថិតនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ដែលមានលិខិតបញ្ជាក់ដីធ្លី ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០២១ ។
5. ដី(ផ្ទះល្វែង)មួយកន្លែង មានក្បាលដីលេខ **៤១** ទំហំ**៤ម៉ែត្រ** គុណនឹង **១៧ម៉ែត្រ** មានទីតាំងស្ថិតនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ។
6. ដីមួយកន្លែង មានទំហំ**៣០ម²** គុណនឹង**៩៧ម²** បូក**១០២ម²** បូក **២៦ម²** បូក**៦៤ម²** បូក **៦៥ម²** មានទីតាំងស្ថិតនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប ។

៣- ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ដើមចោទ។

**ខ- ខ្លឹមសារនៃសាលក្រមដែលចុងចម្លើយ(ដើមចោទនៃបណ្តឹងតប)ទាមទារតបឲ្យតុលាការចេញ**

**១-** ឲ្យដើមចោទឈ្មោះ [redacted] **លឹម** លែងលះពីចុងចម្លើយឈ្មោះ [redacted] **ស្រីមុំ** ។

**២-** ច្រានចោលការទាមទារត្រង់ចំណុចទី២ ដែលមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០២២ របស់ដើមចោទ ។

**៣-** បែងចែកទ្រព្យរួមដូចខាងក្រោម ៖

**ក- ប្រគល់ឲ្យដើមចោទនូវ៖**

ក.១- ដីមួយកន្លែង មានទំហំ **៣៥៨០ម៉ែត្រការ៉េ** ទីតាំងនៅភូមិគោកញ្ចៅ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប មានកិច្ចសន្យាផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៣១៩/០៨ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០០៨។

ក.២- ដីមួយកន្លែងមានទំហំ **២១៧០ម៉ែត្រការ៉េ** ទីតាំងនៅភូមិដូនកែវ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៤៦៩/០៧ ឃដក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០០៧។

ក.៣- ដីមួយកន្លែងមានទំហំ **២២០០ម៉ែត្រការ៉េ** ទីតាំងនៅភូមិទួលប្រាសាទ ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៦៩៤/០៧ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៧ ។

ក.៤- ដីមួយកន្លែងមានទំហំ **២០០០ម៉ែត្រការ៉េ** ទីតាំងនៅភូមិទួលប្រាសាទ ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៦៩៥/០៧ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៧ ។

ក.៥- ដីមួយកន្លែងមានទំហំ ៤០០ ម៉ែត្រការ៉េ ទីតាំងនៅភូមិអារក្សស្វាយ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ១៣៤១/០៧ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៧ ។



Scanned with CamScanner

ក.៦- រថយន្ត ម៉ាក TOYOTA REVO Rally ឆ្នាំ២០១៩ ចំនួន០១គ្រឿង ។

ក.៧- ខ្សែកផ្លាទីន ទម្ងន់ ៣៥៥០ហ៊ុន ។

**ខ- ប្រគល់ឲ្យចុងចម្លើយនូវ៖**

ខ.១- ដីមួយកន្លែងទំហំ **២៧១៥**ម៉ែត្រការ៉េ និងផ្ទះ ទីតាំងនៅភូមិពួកចាស់ ឃុំពួក ស្រុកពួក ខេត្តសៀមរាប មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧០៧១០០១-១០១៥ ចុះថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ ២០១៩ ។

ខ.២- ដីមួយកន្លែងទំហំ ១១៤ ម៉ែត្រការ៉េ និងផ្ទះ ទីតាំងនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៤០៥-០៧០៣ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ។

ខ.៣- ដីមួយកន្លែង និងផ្ទះ ទីតាំងនៅភូមិចំហក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប មាន មានបង្កាន់ដៃចុះបញ្ជីក្បាលដីលេខ ៤១ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ។

ខ.៤- ដីមួយកន្លែងទំហំ ១៥០០ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៦០២/០៧ ឃ.ស.ស ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧ ។

ខ.៥- ដីមួយកន្លែងទំហំ ១១៦២,៥ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលេខ ៧៤៥/០៧ ឃ.ស.ស ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០០៧ ។

ខ.៦- ដីមួយកន្លែងទំហំ ១៥០០ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលេខ ៣១១/០៨ ឃ.ស.ស ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០០៨ ។

៤- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទ ។

## ខ- ដំណើររឿងក្តី និងចំណុចវិវាទ

### ខ.១-ការសង្ខេបអំពីរឿងក្តី

នៅក្នុងរឿងក្តីនេះ ដើមចោទនិងចុងចម្លើយបានអះអាងដូចគ្នាថា ពួកខ្លួនរស់នៅជាមួយគ្នាមិនមានក្តីសុខ មិនចុះសម្រុងនឹងគ្នា និងធ្វើឲ្យខ្លួនមិនអាចទ្រាំរួមរស់ជាមួយគ្នាបន្តទៀតបាន ហើយគូភាគីក៏បានព្រមព្រៀងលែងលះពីគ្នាផងដែរ ។ ក្រៅពីការទាមទារអំពីការលែងលះរវាងដើមចោទនិងចុងចម្លើយរួចហើយ ដើមចោទនិងចុងចម្លើយ ក៏សុំទាមទារនូវការបែងចែកទ្រព្យសម្បត្តិរួមរបស់ពួកខ្លួនផងដែរ ។

### ខ.២- ចំណុចវិវាទ

ខ.២.១-តើទ្រព្យសម្បត្តិរួមខាងលើក្នុងសំណុំរឿងនេះ តុលាការត្រូវសម្រេចបែងចែកយ៉ាងដូចម៉េច?

## គ- ការអះអាងរបស់គូភាគី

### គ.១- ការអះអាងរបស់ដើមចោទ(ចុងចម្លើយនៃបណ្តឹងតប)

-ដើមចោទឈ្មោះ [redacted] លឹម បានធ្វើសេចក្តីថ្លែងការណ៍ថាខ្លួននៅតែសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ស្រីមុំ ដោយហេតុថាខ្លួននិងចុងចម្លើយ មិនអាចយកគ្នាជាប្តីប្រពន្ធវិញបានទេ រស់នៅជាមួយគ្នាមិនមានសេចក្តីសុខ មិនចុះសម្រុងនឹងគ្នា រឿងធ្ងន់ធ្ងរបំផុត ចុងចម្លើយបានជេរប្រមាថខ្លួន ដែលមិនអាចស៊ូទ្រាំរស់នៅជាមួយគ្នាជាប្រពន្ធខ្លួនបន្តទៀតបានទេ ។



Scanned with CamScanner

-ដើមចោទឈ្មោះ [redacted] លឹម បានធ្វើសេចក្តីថ្លែងការណ៍បន្ថែមថាខ្លួនសុំទាមទារគ្រប់គ្រងទ្រព្យសម្បត្តិដូចជា៖

១- ដីមួយកន្លែងទំហំ ១១៤ ម៉ែត្រការ៉េ និងផ្ទះ ទីតាំងនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៤០៥-០៧០៣ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ។

២- ដីមួយកន្លែងទំហំ១៥០០ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៦០២/០៧ ឃ.ស.ស ចុះថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ ២០០៧ ។

៣- ដីមួយកន្លែងទំហំ ១១៦២,៥ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលេខ ៧៤៥/០៧ ឃ.ស.ស ចុះថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០០៧ ។

៤- ដីមួយកន្លែងទំហំ ១៥០០ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលេខ ៣១១/០៨ ឃ.ស.ស ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០០៨ ។

៥- ដីមួយកន្លែង មានទំហំ ៣៥៨០ម៉ែត្រការ៉េ ទីតាំងនៅភូមិគោកញ្ចៅ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប មានកិច្ចសន្យាផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៣១៩/០៨ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០០៨។

៦- ដីមួយកន្លែងមានទំហំ ២១៧០ម៉ែត្រការ៉េ ទីតាំងនៅភូមិដូនកែវ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៤៦៩/០៧ ឃដក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០០៧។

៧- ដីមួយកន្លែងមានទំហំ ២២០០ម៉ែត្រការ៉េ ទីតាំងនៅភូមិទួលប្រាសាទ ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៦៩៤/០៧ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០០៧ ។

៨- ដីមួយកន្លែងមានទំហំ ២០០០ម៉ែត្រការ៉េ ទីតាំងនៅភូមិទួលប្រាសាទ ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៦៩៥/០៧ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០០៧ ។

៩- ដីមួយកន្លែងមានទំហំ ៤០០ម៉ែត្រការ៉េ ទីតាំងនៅភូមិអារក្សស្វាយ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ១៣៤១/០៧ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៧ ។

-ដើមចោទឈ្មោះ [redacted] លឹម បានធ្វើសេចក្តីថ្លែងការណ៍បន្តថាបើខ្លួនទាមទារប៉ុណ្ណឹងមិនបាន និងថាការទាមទាររបស់ខ្លួននេះជ្រុលហួសហេតុពេក ខ្លួនសុំចែកទ្រព្យសម្បត្តិស្មើ ហើយបើមិនអីចឹងទេ ខ្លួនសុំទាមទារដីនិងផ្ទះនៅផ្សារពួកវិញ ដោយទ្រព្យសម្បត្តិដីនៅសល់ទាំងប៉ុន្មានឲ្យចុងចម្លើយទាំងអស់វិញ ។

**គ.២- ការអះអាងរបស់ចុងចម្លើយ(ដើមចោទនៃបណ្តឹងតប)**

-ចុងចម្លើយឈ្មោះ [redacted] ស្រីមុំ បានធ្វើសេចក្តីថ្លែងការណ៍តបថាខ្លួនក៏សុំលែងលះពីដើមចោទឈ្មោះ [redacted] លឹម ផងដែរ ដោយហេតុថាការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ មិនមានសេចក្តីសុខ មិនចុះសម្រុងនឹងគ្នា និងភាគីដើមចោទបានចុះចោលខ្លួនពីផ្ទះ និងក្បត់ខ្លួនផងដែរ ។

-លោកមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍តបថានៅក្នុងពាក្យបណ្តឹងតប ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២ ដោយក្នុងនោះកូនក្តីរបស់ខ្លួនឈ្មោះ [redacted] ស្រីមុំ សុំលែងលះពីដើមចោទឈ្មោះ [redacted] លឹម និងសុំប្រានចោលការទាមទាររបស់ដើមចោទក្នុងចំណុចទី២ ដែលមានក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២ ដោយកូនក្តីរបស់ខ្លួនសុំទាមទារបែងចែកទ្រព្យ ដូចក្នុងពាក្យបណ្តឹងតប ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០២២ ដោយក្នុងចំណុចទី៣ បែងចែកទ្រព្យរួម ក្នុងចំណុច ក ចាប់ពីក.១ រហូតដល់ ក.៧ ប្រគល់ឲ្យដើមចោទ និងគ្រង់ចំណុច ខ (ចាប់ពីចំណុច ខ.១ រហូតដល់ចំណុច ខ.៦) ប្រគល់ឲ្យចុងចម្លើយ ដោយលើកលែងតែចំណុច ខ.២ ដោយក្តីខ្លួនលះបង់ការទាមទារប្រគល់ដីមួយកន្លែងទំហំ **១១៤** ម៉ែត្រការ៉េ និងផ្ទះ ទីតាំងនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៤០៥-០៧០៣ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ នោះទៅឲ្យដើមចោទវិញ ។ ក្រៅពីនេះខ្លួននៅរក្សាការទាមទារដដែល ។

-មេធាវី [redacted] បានថ្លែងការណ៍ថាខ្លួនឯកភាពដូចគ្នានឹងការថ្លែងការណ៍របស់សហភាតាខាងលើ ។

-មេធាវី [redacted] និងមេធាវី [redacted] បានថ្លែងការណ៍តបថាការទាមទាររបស់ដើមចោទមានលក្ខណៈច្រើនជ្រុលហួសហេតុពេក ហើយដើមចោទក៏បានយកទ្រព្យសម្បត្តិមួយចំនួនទៅជាមួយរួចរាល់ផងដែរមានរថយន្ត និងខ្សែកផ្លាទីនជាដើម ។

**ឃ- តស្តុងតាងជាឯកសាររបស់គូភាគីសុំឲ្យតុលាការពិនិត្យ៖**

១- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលសំបុត្រអាពាហ៍ពិពាហ៍លេខ ៣៧ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១៩ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ ២០១៩ រវាងឈ្មោះ [redacted] លឹម និងឈ្មោះ [redacted] ស្រីមុំ ចេញដោយមេឃុំពួក ។

២- សៀវភៅស្នាក់នៅលេខ ២២១២ ប.ក្បាលទី១០ ទំព័រ ២៨៦៩ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ ២០១០ ចេញដោយអធិការនគរបាលស្រុកពួក ។

៣- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ **១៧០៧១០០១-១០១៥** ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០១៩ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្តសៀមរាប ។

៤- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ **១៧១០០៤០៥-០៧០៣** ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្តសៀមរាប ។

៥- លិខិតសុំបញ្ជាក់ដីធ្លី ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ ។

៦- លិខិតបញ្ជាក់ដីធ្លី ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ ។



Scanned with CamScanner

៧- បង្កាន់ដៃចុះបញ្ជីក្បាលដីលេខ ៤១ មានទីតាំងស្ថិតនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប។

៨- កិច្ចសន្យាផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៣១៩/០៨ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៨។

៩- លិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៤៦៩/០៧ ឃដក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៧។

១០- លិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៦៩៤/០៧ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៧ ។

១១- លិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៦៩៥/០៧ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៧ ។

១២- លិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ១៣៤១/០៧ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ ២០០៧ ។

១៣- បង្កាន់ដៃទទួលប្រាក់ ពីក្រុមហ៊ុនតូយូតា(ខេមបូឌា) សាខាខេត្តសៀមរាប ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ ។

១៤- បង្កាន់ដៃ ខ្សែកផ្លាទីន ទម្ងន់៣៥៥០ហ៊ុន ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៨។

១៥- លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ៦០២/០៧ ឃ.ស.ស ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៧ ។

១៦- លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលេខ ៧៤៥/០៧ ឃ.ស.ស ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០០៧ ។

១៧- លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលេខ ៣១១/០៨ ឃ.ស.ស ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០០៨ ។

**គ- ការទាញហេតុផលចុងក្រោយរបស់ដើមចោទ(ចុងចម្លើយនៃបណ្តឹងតប)**

-ដើមចោទឈ្មោះ [redacted] លីម បានធ្វើការទាញហេតុផលចុងក្រោយថាចំពោះដីនិងផ្ទះនៅផ្សារពួក អាចលក់បានរហូតដល់ជាង២០០.០០០(ម្ភៃម៉ឺន)ដុល្លារអាមេរិក ហើយបើការទាមទាររបស់ខ្លួនប៉ុណ្ណឹង ជ្រុលហួសហេតុពេក មិនបានទេ ខ្លួនសុំឲ្យតុលាការបែងចែកទ្រព្យសម្បត្តិស្មើគ្នា ។

**ឃ- ការទាញហេផលចុងក្រោយរបស់ចុងចម្លើយ(ដើមចោទនៃបណ្តឹងតប)**

មេធាវី [redacted] បានធ្វើការទាញហេតុផលចុងក្រោយថាខ្លួនជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ សុំរក្សាការទាមទារដូចនៅក្នុងបណ្តឹងតបដដែល ដោយកូនក្តីខ្លួនយល់ព្រមលះបង់នូវទ្រព្យសម្បត្តិដីនៅជន្លង់ ចំណុច ខ.២ ក្រៅពីនេះនៅរក្សាទាមទារនិងប្រគល់ឲ្យដើមចោទដដែល មានចំណុច ខ.១ ខ.៣ ខ.៣ ខ.៤ ខ.៥ និងចំណុច ខ.៦ ហើយដើមចោទបាននាំយកទៅជាមួយនូវរថយន្ត តម្លៃថ្មីជាង ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក និងខ្សែករផ្លាទីន តម្លៃជាង៣,០០០(បីពាន់)ដុល្លារអាមេរិក ។ ផ្ទះនិងដីនៅជន្លង់ ទិញក្នុងតម្លៃរហូតដល់ ១២០,០០០(ដប់ពីរម៉ឺន)ដុល្លារអាមេរិក ហើយបើដើមចោទលក់អាចបានថ្លៃលើសនេះទៅទៀត ។ បើយោងតាមមាត្រា៩៨០ ចំណុច ២ ចំណុច ខ នៃក្រមរដ្ឋប្បវេណី ចែងថា បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម។ ប៉ុន្តែ បើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជាទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគ របស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវ

ចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូនជាអាទិ៍។ ដើមចោទជាប្ដីបានចាកចេញពីផ្ទះ ហើយកន្លែងពេទ្យធ្មេញ ដែលកូនក្ដីខ្លួន និងកូនគាត់ខំបណ្ដុះបណ្ដាលមក គឺជាឆ្នាំងបាយរបស់ចុងចម្លើយសម្រាប់ចិញ្ចឹមកូន ហើយដើមចោទក៏បានចាកចេញ និងយករបស់របរមានតម្លៃទៅជាមួយរួចហើយផងដែរ ។ ដីនៅក្រោយផ្សាររលើ ក្នុងភូមិជន្លង់ ដើមចោទបានទាមទារ ហើយចុងចម្លើយក៏បានប្រគល់ឲ្យហើយ អ៊ីចឹងដើមចោទមិនគួរទាមទារដីបន្ថែមទៀតនៅខាងសសរស្ដម្ភ និងដីផ្សេងទៀតនោះទេ ។ ដូច្នេះ ខ្លួនសុំឲ្យតុលាការពិចារណា និងបែងចែកទ្រព្យសម្បត្តិតាមបណ្ដឹងតបដដែល ។

-មេធាវី [redacted] បានធ្វើការទាញហេតុផលចុងក្រោយថាបណ្ដឹងទាមទាររបស់កូនក្ដីខ្លួនមានសមាមាត្រហើយ ការសុំទាមទារបែងចែកទ្រព្យសម្បត្តិរបស់ដើមចោទ អាចលើសពីការសុំបែងចែកពីលើកមុនទៀត ហើយកូនក្ដីខ្លួនជាស្រីមេផ្ទះនៅជាមួយកូន ហើយពឹងលើកូនបើករបរពេទ្យធ្មេញនៅដីនិងផ្ទះនៅផ្សារពួក ហើយដីនៅសសរស្ដម្ភ កូនក្ដីខ្លួនទុកអាស្រ័យផលនៅក្រោយពេលគាត់ចាស់ទៅ ។ ដើមចោទអាចយកដីនិងផ្ទះនៅជន្លង់ដើម្បីប្រកបមុខរបរវិជ្ជាជីវៈរបស់គាត់បាន ។

## សំអាងហេតុ

**១**- ពាក្យបណ្ដឹងអង្គសេចក្ដី ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] **លឹម** ធ្វើឡើងត្រឹមត្រូវតាមច្បាប់ តុលាការអាចលើកយកមកធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន តាមបញ្ញត្តិមាត្រា១០ និងមាត្រា ២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**២**- ពាក្យបណ្ដឹងតប ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] **ស្រីមុំ** ដែលលោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ តុលាការគប្បីមានសមត្ថកិច្ចទទួលដោះស្រាយ និង វិនិច្ឆ័យលើបណ្ដឹងនេះ ស្របតាមបញ្ញត្តិមាត្រា៨៦ មាត្រា៧ និងមាត្រា១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**៣**- បណ្ដឹង និងបណ្ដឹងតបខាងលើ គឺជាការទាមទារដែលទាក់ទងនឹងសិទ្ធិ ផលប្រយោជន៍ និងទំនាក់ទំនងគតិយុត្ត រវាងដើមចោទជាប្ដី និងចុងចម្លើយជាប្រពន្ធ ដែលកម្មវត្ថុចម្បងរបស់ភាគីដើមចោទនិងចុងចម្លើយសុំទាមទារលែងលះ និងបែងចែកទ្រព្យសម្បត្តិរួម ។ ហេតុនេះសាលាដំបូងខេត្តសៀមរាប ដែលបណ្ដឹងដែលត្រូវបានដាក់មកឱ្យវិនិច្ឆ័យ និងចេញសាលក្រមនេះ គឺជាតុលាការមានសមត្ថកិច្ចជម្រះក្ដី ។

**៤**- តាមសេចក្ដីថ្លែងការណ៍របស់ដើមចោទ និង ចុងចម្លើយ មេធាវីតំណាងដោយអាណត្តិ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់ រួមទាំងការពិនិត្យកស្តុតាងជាឯកសារនានា ដែលមានក្នុងសំណុំរឿង តុលាការយល់ឃើញថា៖

**៥- ការវិនិច្ឆ័យចំពោះការទាមទារលែងលះ**

៥.១- ដើមចោទឈ្មោះ [redacted] **លឹម** និងចុងចម្លើយឈ្មោះ [redacted] **ស្រីមុំ** ពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ៣៧ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១៩ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមានសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ ត្រឹមត្រូវតាមច្បាប់ ប្រាកដមែន។

៥.២- ក្រោយពេលរួមរស់នៅជាមួយគ្នា និងការអះអាងរបស់ដើមចោទ អំពីមូលហេតុនៃការលែងលះថាខ្លួននិងចុងចម្លើយ មិនអាចយកគ្នាជាប្តីប្រពន្ធវិញទេ រស់នៅជាមួយគ្នាមិនមានសេចក្តីសុខ មិនចុះសម្រុងនឹងគ្នា និងរឿងធ្ងន់ធ្ងរចុងចម្លើយបានជេរប្រមាថខ្លួន ដែលមិនអាចស៊ូទ្រាំរស់នៅជាមួយគ្នាជាប្រពន្ធរស់ខ្លួនបន្តទៀតបាន ហើយចុងចម្លើយបានអះអាងតបវិញថាខ្លួនក៏សុំលែងលះពីដើមចោទផងដែរ ដោយហេតុថាការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ មិនមានសេចក្តីសុខ មិនចុះសម្រុងនឹងគ្នា និងភាគីដើមចោទបានចុះចោលខ្លួនពីផ្ទះ និងក្បត់ខ្លួនផងដែរ ។

៥.៣- តាមការអះអាងរបស់ដើមចោទ និងចុងចម្លើយឃើញថា ពួកខ្លួនមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ទេ ហើយទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទជាមួយនឹងចុងចម្លើយបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទេ ដូច្នេះមានមូលហេតុនៃការលែងលះ ដូចមានចែងក្នុងចំណុច ង កថាខណ្ឌទី១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ដែលតុលាការគប្បីសម្រេចឲ្យគូភាគីលែងលះពីគ្នា ។

**៦- ការវិនិច្ឆ័យចំពោះការបែងចែកទ្រព្យសម្បត្តិ**

៦.១- គូភាគីបានអះអាងថាក្នុងអំឡុងពេលរស់នៅជាមួយគ្នា មានទ្រព្យសម្បត្តិរួម ដូចខាងក្រោម៖

១- ដីមួយកន្លែង មានទំហំ **២៧១៥ម²** មានទីតាំងស្ថិតនៅភូមិពួកចាស់ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧០៧១០០១-១០១៥ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ ។

២- ដីមួយកន្លែង មានទំហំ **១១៤ម²** មានទីតាំងស្ថិតនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៤០៥-០៧០៣ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ។

៣- ដីស្រែមួយកន្លែង មានទំហំ **៣៧៩៥ម²** មានទីតាំងស្ថិតនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ដែលមានលិខិតសុំបញ្ជាក់ដីធ្លី ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ ។

៤- ដីស្រែមួយកន្លែង មានទំហំ **១៩២០ម²** មានទីតាំងស្ថិតនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ដែលមានលិខិតបញ្ជាក់ដីធ្លី ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ ។

៥- ដីមួយកន្លែង មានទំហំ ៣៥៨០ម៉ែត្រការ៉េ ទីតាំងនៅភូមិគោកញ្ចៅ ឃុំដូនកែវ ស្រុកពួក ខេត្តសៀរាប មានកិច្ចសន្យាផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៣១៩/០៨ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០០៨ ។

៦- ដីមួយកន្លែងមានទំហំ **២១៧០**ម៉ែត្រការ៉េ ទីតាំងនៅភូមិដូនកែវ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៤៦៩/០៧ យដក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០០៧ ។

៧- ដីមួយកន្លែងមានទំហំ **២២០០**ម៉ែត្រការ៉េ ទីតាំងនៅភូមិទួលប្រាសាទ ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៦៩៤/០៧ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០០៧ ។

៨- ដីមួយកន្លែងមានទំហំ **២០០០**ម៉ែត្រការ៉េ ទីតាំងនៅភូមិទួលប្រាសាទ ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៦៩៥/០៧ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០០៧ ។



Scanned with CamScanner

៩- ដីមួយកន្លែងមានទំហំ ៤០០ ម៉ែត្រការ៉េ ទីតាំងនៅភូមិអារក្សស្វាយ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ១៣៤១/០៧ ចុះថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ ២០០៧ ។

១០-រថយន្ត ម៉ាក TOYOTA REVO Rally ឆ្នាំ២០១៩ ចំនួន០១គ្រឿង ។

១១-ខ្សែកផ្កាទីន ទម្ងន់ **៣៥៥០**ហ៊ុន ។

១២- ដីមួយកន្លែង និងផ្ទះ ទីតាំងនៅភូមិចំហក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប មានមានបង្កាន់ដៃចុះបញ្ជីក្បាលដីលេខ **៤១** ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ។

១៣- ដីមួយកន្លែងទំហំ **១៥០០**ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ៦០២/០៧ ឃ.ស.ស ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៧ ។

១៤- ដីមួយកន្លែងទំហំ **១១៦២,៥**ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលេខ ៧៤៥/០៧ ឃ.ស.ស ចុះថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០០៧ ។

១៥- ដីមួយកន្លែងទំហំ **១៥០០**ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលេខ ៣១១/០៨ ឃ.ស.ស ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ ។

ដោយភាគីដើមចោទសុំទាមទារគ្រប់គ្រងនូវទ្រព្យសម្បត្តិ មានដូចជា៖

១- ដីមួយកន្លែងទំហំ **១១៤** ម៉ែត្រការ៉េ និងផ្ទះ ទីតាំងនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៤០៥-០៧០៣ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ។

២- ដីមួយកន្លែងទំហំ១៥០០ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ៦០២/០៧ ឃ.ស.ស ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ។

៣- ដីមួយកន្លែងទំហំ **១១៦២,៥**ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលេខ ៧៤៥/០៧ ឃ.ស.ស ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៧ ។

៤- ដីមួយកន្លែងទំហំ **១៥០០**ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលេខ ៣១១/០៨ ឃ.ស.ស ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ ។

៥- ដីមួយកន្លែង មានទំហំ **៣៥៨០**ម៉ែត្រការ៉េ ទីតាំងនៅភូមិគោកញ្ចៅ ឃុំដូនកែវ ស្រុកពួក ខេត្តសៀរាប មានកិច្ចសន្យាផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៣១៩/០៨ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០០៨ ។



Scanned with CamScanner

៦- ដីមួយកន្លែងមានទំហំ **២១៧០**ម៉ែត្រការ៉េ ទីតាំងនៅភូមិដូនកែវ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៤៦៩/០៧ ឃដក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០០៧ ។

៧- ដីមួយកន្លែងមានទំហំ **២២០០**ម៉ែត្រការ៉េ ទីតាំងនៅភូមិទួលប្រាសាទ ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៦៩៤/០៧ ចុះថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ ២០០៧ ។

៨- ដីមួយកន្លែងមានទំហំ **២០០០**ម៉ែត្រការ៉េ ទីតាំងនៅភូមិទួលប្រាសាទ ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៦៩៥/០៧ ចុះថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ ២០០៧ ។

៩- ដីមួយកន្លែងមានទំហំ **៤០០**ម៉ែត្រការ៉េ ទីតាំងនៅភូមិអារក្សស្វាយ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ១៣៤១/០៧ ចុះថ្ងៃទី០៤ ខែ កក្កដា ឆ្នាំ២០០៧ ។

តែចុងចម្លើយមិនយល់ព្រម ដោយខ្លួនយល់ព្រមលះបង់នូវការទាមទារឲ្យដើមចោទតែដីមួយកន្លែងទំហំ **១១៤**ម៉ែត្រការ៉េ និងផ្ទះ ទីតាំងនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៤០៥-០៧០៣ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០១៩ ប៉ុណ្ណោះ ។

**៦.២**- នៅក្នុងពាក្យបណ្តឹង និងបណ្តឹងតប នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទ សុំទាមទារបែងចែកទ្រព្យសម្បត្តិទាំងអស់ខាងក្រោម ហើយចុងចម្លើយ និងមេធាវីតំណាងដោយអាណត្តិ ក៏បានសុខចិត្តប្រគល់ទៅឲ្យដើមចោទនូវ៖

១- ដីមួយកន្លែង មានទំហំ **៣៥៨០**ម៉ែត្រការ៉េ ទីតាំងនៅភូមិគោកញ្ចៅ ឃុំដូនកែវ ស្រុកពួក ខេត្តសៀរាប មានកិច្ចសន្យាផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៣១៩/០៨ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៨ ។

២- ដីមួយកន្លែងមានទំហំ **២១៧០**ម៉ែត្រការ៉េ ទីតាំងនៅភូមិដូនកែវ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៤៦៩/០៧ ឃដក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៧ ។

៣- ដីមួយកន្លែងមានទំហំ **២២០០**ម៉ែត្រការ៉េ ទីតាំងនៅភូមិទួលប្រាសាទ ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៦៩៤/០៧ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៧ ។

៤- ដីមួយកន្លែងមានទំហំ **២០០០**ម៉ែត្រការ៉េ ទីតាំងនៅភូមិទួលប្រាសាទ ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៦៩៥/០៧ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៧ ។

៥- ដីមួយកន្លែងមានទំហំ ៤០០ ម៉ែត្រការ៉េ ទីតាំងនៅភូមិអារក្សស្វាយ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ១៣៤១/០៧ ចុះថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០០៧ ។



Scanned with CamScanner

៦- រថយន្ត ម៉ាក TOYOTA REVO Rally ឆ្នាំ២០១៩ ចំនួន០១គ្រឿង ។

៧- ខ្សែកផ្កាទីន ទម្ងន់ **៣៥៥០**ហ៊ុន ។

តុលាការយល់ឃើញថា ចុងចម្លើយយល់ព្រមប្រគល់ទៅឲ្យដើមចោទហើយ តាមពាក្យបណ្តឹងតប និងដើមចោទក៏ទាមទារផងដែរ ដូច្នេះតុលាការគប្បីសម្រេចតាមការទាមទាររបស់គូភាគីប្រគល់ទៅឲ្យដើមចោទ។

៦.៣- ដោយឡែកចំពោះទ្រព្យសម្បត្តិរួមមានដូចខាងក្រោម៖

១- ដីមួយកន្លែងទំហំ **២៧១៥**ម៉ែត្រការ៉េ និងផ្ទះ ទីតាំងនៅភូមិពួកចាស់ ឃុំពួក ស្រុកពួក ខេត្តសៀមរាប មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧០៧១០០១-១០១៥ ចុះថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ ២០១៩ ។

២- ដីមួយកន្លែងទំហំ **១១៤** ម៉ែត្រការ៉េ និងផ្ទះ ទីតាំងនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៤០៥-០៧០៣ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ។

៣- ដីមួយកន្លែង និងផ្ទះ ទីតាំងនៅភូមិចំហក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប មាន មានបង្កាន់ដៃចុះបញ្ជីក្បាលដីលេខ ៤១ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ។

៤- ដីមួយកន្លែងទំហំ **១៥០០**ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៦០២/០៧ ឃ.ស.ស ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ។

៥- ដីមួយកន្លែងទំហំ **១១៦២,៥**ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលេខ ៧៤៥/០៧ ឃ.ស.ស ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៧ ។

៦- ដីមួយកន្លែងទំហំ **១៥០០**ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលេខ ៣១១/០៨ ឃ.ស.ស ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០០៨ ។

៧- ដីស្រែមួយកន្លែង មានទំហំ**៣៧៩៥**ម² មានទីតាំងស្ថិតនៅភូមិគោកញ្ចៅ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប ដែលមានលិខិតសុំបញ្ជាក់ដីធ្លីលេខ ២០០៦.២១ ឃដក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ ។

៨- ដីស្រែមួយកន្លែង មានទំហំ **១៩២០**ម² មានទីតាំងស្ថិតនៅភូមិដូនកែវ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប ដែលមានលិខិតបញ្ជាក់ដីធ្លីលេខ ២០០៧.២១ ឃដក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ ។

គូភាគីនៅតែទាមទារសុំបែងចែកទ្រព្យសម្បត្តិខាងលើនេះរៀងៗខ្លួន ដោយដើមចោទមិនទទួលយកការលះបង់និងប្រគល់ទ្រព្យសម្បត្តិនូវរបស់ចុងចម្លើយនោះទេដោយសុំបែងចែកស្មើគ្នា ហើយក៏ចុងចម្លើយក៏មិនព្រមប្រគល់ទ្រព្យសម្បត្តិខាងលើទៅតាមការទាមទារទៅឲ្យដើមចោទនោះដែរ ។ តុលាការយល់ឃើញថា ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការទាមទារសុំឲ្យបែងចែករវាងដើមចោទ និងចុងចម្លើយនៅ



Scanned with CamScanner

ក្នុងបណ្តឹងដើម និងបណ្តឹងតបនេះ គឺជាទ្រព្យសម្បត្តិដែលប្តីនិងប្រពន្ធ ទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ជាគោលការណ៍នឹងត្រូវក្លាយជាទ្រព្យសម្បត្តិរួម ស្របតាមមាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី ហើយនៅក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម ស្របតាមចំណុច ខ កថាខណ្ឌទី២ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី ។ ការណ៍ដែលលើកឡើងបែបនេះ គឺដោយហេតុថាប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការសង្គ្រោះគ្នាទៅវិញទៅមក ស្របតាមមាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណី ហេតុនេះទ្រព្យសម្បត្តិដែលគូភាគីសុំទាមទារបែងចែកនេះ គឺជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ តាមរយៈការសហការគ្នារវាងប្តីប្រពន្ធ ដូច្នេះនៅពេលលែងលះគ្នា ក៏តុលាការគប្បីយកទ្រព្យសម្បត្តិខាងលើនេះមកធ្វើការបែងចែកគ្នាដោយឲ្យដើមចោទ និងចុងចម្លើយទទួលចំណែកក្នុងម្នាក់ៗ ១ ភាគ ២ ទៅលើទ្រព្យសម្បត្តិរួមខាងលើ ។ ចំពោះការលើកឡើងរបស់មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយថាបើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជាទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគ របស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូន ជាអាទិ៍ តុលាការយល់ឃើញថាពុំមានភាពចាំបាច់នោះទេ ។

**៧- ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី**

ស្តីពីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី តុលាការទទួលស្គាល់អំពីការទាមទាររបស់ដើមចោទនិងចុងចម្លើយពាក់ព័ន្ធនឹងបណ្តឹងទាមទារលែងលះគ្នា តែការទាមទាររបស់ដើមចោទ និងចុងចម្លើយពាក់ព័ន្ធនឹងទាមទារសុំឲ្យបែងទ្រព្យសម្បត្តិរួម ត្រូវបានតុលាការសម្រេចទទួលស្គាល់អំពីមូលហេតុដោយផ្នែកប៉ុណ្ណោះ ។ យោងតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី បន្ទុកនៃប្រាក់ប្រដាប់ក្តីជារបស់ភាគីចាញ់ក្តី ហេតុនេះបន្ទុកនៃប្រាក់ប្រដាប់ក្តី គប្បីតុលាការឲ្យដើមចោទ និងចុងចម្លើយ ទទួលបន្ទុកម្នាក់ៗចំនួន ១ ភាគ ២ ។

**សេចក្តីសម្រេចបញ្ចប់**

១- លែងលះដើមចោទឈ្មោះ [redacted] **លឹម** និងចុងចម្លើយឈ្មោះ [redacted] **ស្រីមុំ** ពីគ្នា ។

២- ប្រគល់ឲ្យដើមចោទនូវទ្រព្យសម្បត្តិ ដូចខាងក្រោម ៖

១- ដីមួយកន្លែង មានទំហំ ៣៥៨០ម៉ែត្រការ៉េ ទីតាំងនៅភូមិគោកញ្ញៅ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប មានកិច្ចសន្យាផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៣១៩/០៨ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៨។

២- ដីមួយកន្លែងមានទំហំ ២១៧០ម៉ែត្រការ៉េ ទីតាំងនៅភូមិដូនកែវ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៤៦៩/០៧ ឃដក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៧។

៣- ដីមួយកន្លែងមានទំហំ ២២០០ម៉ែត្រការ៉េ ទីតាំងនៅភូមិទួលប្រាសាទ ឃុំផ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៦៩៤/០៧ ចុះថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ ២០០៧ ។



Scanned with CamScanner

៤- ដីមួយកន្លែងមានទំហំ ២០០០ម៉ែត្រការ៉េ ទីតាំងនៅភូមិទួលប្រាសាទ ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៦៩៥/០៧ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៧ ។

៥- ដីមួយកន្លែងមានទំហំ ៤០០ ម៉ែត្រការ៉េ ទីតាំងនៅភូមិអារក្សស្វាយ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ១៣៤១/០៧ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៧ ។

៦- រថយន្ត ម៉ាក TOYOTA REVO Rally ឆ្នាំ២០១៩ ចំនួន០១គ្រឿង ។

៧- ខ្សែកផ្លាទីន ទម្ងន់ ៣៥៥០ហ៊ុន ។

៣- បែងចែកទ្រព្យសម្បត្តិនីមួយៗ ឲ្យដើមចោទ និងចុងចម្លើយ ដូចខាងក្រោម៖

១- ដីមួយកន្លែងទំហំ ២៧១៥ម៉ែត្រការ៉េ និងផ្ទះ ទីតាំងនៅភូមិពួកចាស់ ឃុំពួក ស្រុកពួក ខេត្តសៀមរាប មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧០៧១០០១-១០១៥ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ ក្នុងចំណែកម្នាក់ៗចំនួន១ ភាគ ២ (មួយភាគពីរ) ។

២- ដីមួយកន្លែងទំហំ ១១៤ ម៉ែត្រការ៉េ និងផ្ទះ ទីតាំងនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៤០៥-០៧០៣ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ក្នុងចំណែកម្នាក់ៗចំនួន១ ភាគ ២ (មួយភាគពីរ) ។

៣- ដីមួយកន្លែង និងផ្ទះ ទីតាំងនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប មាន មានបង្កាន់ដៃចុះបញ្ជីក្បាលដីលេខ ៤១ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ក្នុងចំណែកម្នាក់ៗចំនួន១ ភាគ ២ (មួយភាគពីរ) ។

៤- ដីមួយកន្លែងទំហំ ១៥០០ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៦០២/០៧ ឃ.ស.ស ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ក្នុងចំណែកម្នាក់ៗចំនួន១ ភាគ ២ (មួយភាគពីរ)។

៥- ដីមួយកន្លែងទំហំ ១១៦២,៥ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលេខ ៧៤៥/០៧ ឃ.ស.ស ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៧ ក្នុងចំណែកម្នាក់ៗចំនួន១ ភាគ២ (មួយភាគពីរ)។

៦- ដីមួយកន្លែងទំហំ ១៥០០ម៉ែត្រការ៉េ ទីតាំងនៅភូមិស្វាយ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលេខ ៣១១/០៨ ឃ.ស.ស ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០០៨ ក្នុងចំណែកម្នាក់ៗចំនួន១ ភាគ ២ (មួយភាគពីរ) ។

៧- ដីស្រែមួយកន្លែង មានទំហំ ៣៧៩៥ម$^{2}$ មានទីតាំងស្ថិតនៅភូមិគោកញៀ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប ដែលមានលិខិតសុំបញ្ជាក់ដីធ្លីលេខ ២០០៦.២១ ឃដក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ ក្នុងចំណែកម្នាក់ៗចំនួន១ ភាគ ២ (មួយភាគពីរ) ។



Scanned with CamScanner

៨- ដីស្រែមួយកន្លែង មានទំហំ **១៩២០ម$^{២}$** មានទីតាំងស្ថិតនៅភូមិដូនកែវ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប ដែលមានលិខិតបញ្ជាក់ដីធ្លីលេខ ២០០៧.២១ ឃដក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ ក្នុងចំណែកម្នាក់ៗចំនួន**១ ភាគ ២** (មួយភាគពីរ) ។

៤- ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីដើមចោទ និងចុងចម្លើយ ចំនួន**៥០%**(ហាសិបភាគរយ) ម្នាក់ (ម្នាក់ពាក់កណ្តាល)។

សាលក្រមនេះ គូភាគីអាចប្តឹងឧទ្ធរណ៍ តាមមាត្រា**២៦០** និងមាត្រា**២៦៤** នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ចៅក្រម**

ហត្ថលេខា និងត្រា[redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃចន្ទ ១៤កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ខេត្តសៀមរាប ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]